**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៤៣៦២ **អយក.** ទ៦៧

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៤

**ជម្រាបជូន**

- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**
- **ឯកឧត្តម នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**
- **ឯកឧត្តម នាយកវិទ្យាស្ថានជាតិអប់រំ**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យស្វាយរៀង**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យកំចាយមារ**
- **លោកជំទាវ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបាត់ដំបង**
- **ឯកឧត្តម សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបន្ទាយមានជ័យ**

**កម្មវត្ថុ** : សំណើសុំផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ទៅសិក្សានៅចក្រភពអង់គ្លេសសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦

**យោង** : លិខិតចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ របស់ The British Deputy Head of Mission នៃចក្រភពអង់គ្លេសនៅរាជធានីភ្នំពេញ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវថា ក្នុងឆ្នាំសិក្សា២០១៥-២០១៦ The British Deputy Head of Mission នៃចក្រភពអង់គ្លេសបានជូនដំណឹងស្តីពីការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សារយៈពេល០១ឆ្នាំតាមកម្មវិធីCHEVENING Scholarship លើមុខវិជ្ជាសិក្សាដូចជា៖

- Good Governance and Human Rights
- Politics and International Relations
- Legal and Judicial Sector
- Economic, Social or Private Sector Development
- Climate Change and Environmental Management

កម្មវិធីអាហារូបករណ៍នេះផ្តល់ឱកាសឲ្យអ្នកចូលរួម ដើម្បីក្លាយជាអ្នកដឹកនាំនាពេលអនាគត សម្រាប់ការកសាងបណ្តាញមូលដ្ឋានគ្រឹះសង្គម វប្បធម៌ ឬដៃគូពាណិជ្ជកម្មជាមួយចក្រភពអង់គ្លេស លើវិជ្ជាជីវៈទទួលបានពីការសិក្សា ។ ព័ត៌មានពាក់ព័ន្ធការចូលរួមកម្មវិធីអហារូបករណ៍ខាងលើនេះអ្នកចូលរួមត្រូវដាក់ពាក្យសុំតាម online ដែលមានគេហទំព័រ www.chenvening.org ។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

កាលបរិច្ឆេទឈប់ទទួលពាក្យសុំត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨វេលាម៉ោង 23.59 GMT។ ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែមសូមទាក់ទងនឹង Ms.Sovannraksmey Chap, Project coordinator, Tel: 023 427 124 Ext: 2218 or sovannrasksmey.chap@fco.gov.uk ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមឯកឧត្តម លោកជំទាវ មេត្តាផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ខាងលើនេះជូនដល់មន្ត្រីសាស្ត្រាចារ្យ ស្ថិតក្រោមឱវាទ ដែលមានលក្ខណសម្បត្តិសមស្រប ចូលរួមជាបេក្ខភាពទទួលអាហារូបករណ៍តាមការគួរ ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

បណ្ឌិត ហង់ ជួន ណារ៉ុន

**ចម្លងជូន**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-នាយកដ្ឋានឧត្តមសិក្សា
-នាយកដ្ឋានបុគ្គលិក
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
-កាលប្បវត្តិ-ឯកសារនៅ.ទវអ